សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

# កិច្ចការស្រាវជ្រាវ

# ទ្រឹស្ដីមួយចំនួនដែលនាំឱ្យកើតមានបទដ្ឋានគតិយុត្ត

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ

-រស់ ឡាលីន -ពៅ ឈីវឡុង

-លន់ ស៊ីណាត -ជៀក ស្រីនាថ

-ស៊ុន ធារី -សុជាតិ វិច្ឆិកា

-លាម លិះ

សាស្ត្រាចារ្យណែនាំ

លោក **ម៉ុក ដារ៉ា**

ថ្នាក់ **បរិញ្ញាបត្រជាន់ខ្ពស់ នីតិសាស្ត្រ**

ជំនាញ **នីតិឯកជន** ជំនាន់១០

ឆ្នាំចូលសិក្សា ២០១៣

ឆ្នាំសរសេរកិច្ចការស្រាវជ្រាវ ២០១៥

**រក្សាសិទ្ធិដោយ** Khmer Famous

# មាតិកា


**សេចក្តីផ្តើម** ........ 1

**១.គំនិតរបស់លោក** MAX WEBER ........ 2

**១.១សមត្ថកិច្ចបច្ចេកទេស** ........ 2

**១.២ឋានានុក្រមនៃអាជ្ញាធរ** ........ 3

**១.៣ច្បាប់ និងបទប្បញ្ញត្តិ** ........ 3

**១.៤ការបែងចែកពលកម្ម** ........ 3

**១.៥ឯកសារជាលាយលក្ខអក្សរ** ........ 3

**១.៦កម្មសិទ្ធិ ឬការត្រួតពិនិត្យរបស់អង្គការចាត់តាំងនីមួយៗ** ........ 4

**២.កំណើតដែលទាក់ទងនិងការកកើតអត្ថបទគតិយុត្ត** ........ 4

**៣.ទ្រឹស្តីរបស់លោក** Thomas Paine ........ 6

៤.Oliver Wendell Holmes, Jr. ........ 6

**៥.ខុន ជឺ** ........ 8

**៦. ជីវប្រវត្តិសង្ខេបរបស់លោក លោក សង់ សាក់រ៉ូសូ** ........ 11

**៦.១ អំពីទ្រឹស្តីរបស់ លោក សង់ សាក់រ៉ូសូ** ........ 11

**៦.២ ប្រព័ន្ធរាជាធិបតេយ្យ** ........ 12

**៦.៣ ប្រព័ន្ធប្រជាធិបតេយ្យ** ........ 13

**៧.ស្សុន:លោក**G.W.F HEGEL ........ 14

**៧.១ទស្សនវិជ្ជាច្បាប់** ........ 15

**៧.២ទស្សនវិជ្ជាភាពខុសគ្នានៃសង្គមស៊ីវិល នយោបាយ និងរដ្ឋ** ........ 15

**៧.៣ទស្សនវិជ្ជាអំពីឋានានុក្រមរបស់រដ្ឋ** ........ 16

**៨ ទស្សនៈរបស់លោក ស៊ុន យ៉ាត់សេន** ........ 17

**៨.១ទស្សនវិជ្ជាអំពីគំនិតនយោបាយ** ........ 17

**៨.៣ទស្សនៈ  ស៊ុន យ៉ាត់សេន អំពីអត្ថនយ័នៃរដ្ឋធម្មនុញ្ញ** ........ 19

**៩.ទស្សនៈវិទូលោក ម៉ៅ សេទុង អំពីការកកើត ច្បាប់ និងរដ្ឋ** ........ 19

**ឯកសារយោង** ........ i

Oliver Wendell Holmes, Jr. ........ i

Abrams v. United States ........ iv

Buck v. Bell ........ v

# សេចក្តីផ្តើម

នាពេលបច្ចុប្បន្នភាពនៃគ្រប់បណ្តាប្រទេសលើសកលោក គឺមានសេរីភាព ជាងពេលណាៗទាំងអស់នៅក្នុងដំណើរប្រវត្តិសាស្ត្ររបស់ប្រទេសរបស់ខ្លួន។ ប្រទេសនិមួយៗរមែងតែមាននូវ អ្នកប្រាជ្ញ ល្បីៗ ដែលគាត់បានបន្សល់ទុកនូវ ស្នាដៃដ៏មានតំលៃមកអោយ មនុស្សជំនាន់ក្រោយ ដើម្បីអភិវឌ្ឍន៍ប្រទេសរៀងខ្លួន ទៅតាមទស្សនៈនិង ទ្រឹស្តីនៃការកកើតបទដ្ឋានគតិយុត្ត របស់គាត់។ ប្រទេសមួយអាចរីកចំរើននិងមានការអភិវឌ្ឍន៍គឺ អាស្រយ័ទៅនិងកត្តា ជាច្រើន រួមមានកត្តាសេដ្ឋកិច្ចនយោបាយ និងជាពិសេស ការកកើតគតិយុត្ត ហើយ ប្រទេសមួយ អាចបង្កើតនូវរដ្ឋមួយអាស្រយ័ដោយមានការចូលរួមដោយ ច្បាប់ ព្រោះថារដ្ឋនិង ច្បាប់មិនអាចនូវដាច់ដោយឡែកពីគ្នាបានទេ ។ យ៉ាងណាមិញ ទស្សនវិទូនីមួយគាត់សុទ្ធសឹងតែមានទស្សនៈនិង ទ្រឹស្តី ផ្សេងៗគ្នាទៅតាមការយល់ដឹង ការស្រាវជ្រាវ និងទៅតាមតំណាក់កាលនៃ សមយ័ កាលនីមួយៗ ។ ដើម្បីឲ្យយល់ការតែច្បាស់ ថាតើទស្សនវិទូ នីមួយគាត់មានទស្សនៈ និងទ្រឹស្តីបែបណា ចំពោះការកកើតបទដ្ឋានគតិយុត្ត ? ក្រុមយើងខ្ញុំសូមលើកឡើង នូវ ប្រធានបទអំពី ៉ ទ្រឹស្តីមួយចំនួនដែលនាំអោយកកើតបទដ្ឋានគត្តិយុត្ត ។

## ១.គំនិតរបស់លោក MAX WEBER

លោក MAX WEBER ជាសេដ្ឋវិទូ និងនយោបាយវិទូរជនជាតិ អាល្លឺម៉ង់ ។ លោក បាននាំមក នូវសមិទ្ធិផលយ៉ាងច្រើន នៅក្នុងការអភិវឌ្ឍនយោបាយ ក្នុងនោះរាប់បញ្ចូល ស្នាដៃលោកអំពី″ **ភាពជាម្ចាស់ និងសង្គម″ ‶សង្គមវិទ្យា និងសាសនា″ ‶មនោគមវិទ្យាប្រូតេស្តង់ និងព្រលឹង របបមូលធននិយម″**។

លោក Weber យល់ថាសង្គមរីកចំរើនបានដោយសំអាងលើកត្តាពីរយ៉ាងគឺ កត្តាសំភារះ និង ស្មារតី។ លោកបានធ្វើការរិះគន់លើរបបមូលធននិយម ដែលដឹកនាំប្រទេស ដោយប្រើប្រាស់ មូលដ្ឋានរបបការិយាធិបតេយ្យ ដែលយកចិត្តទុកដាក់យ៉ាងខ្លាំងលើបុណ្យ ស័ក្តិ។

លោក Weber យល់ថាកិច្ចការដឹកនាំសង្គមគួរតែចូលរួមយ៉ាងសកម្មពីសំណាក់មហាជន ដោយជំរុញឲ្យមហាជនចេះប្រើសិទ្ធិរបស់ខ្លួនក្នុងការជ្រើសរើសអ្នកដឹកនាំ។

លោក Weber យល់ថាការគោរពតាមជំនឿប្រូតេស្តង់ មានការជឿនលឿន ជាងកាតាលិក ពីព្រោះវាប្រៀបដូចជាការអនុវត្តទីផ្សាសេរី និងធ្វើឲ្យមានកំណើនសេដ្ឋកិច្ចឆាប់ រហ័ស។

លោក Max Weber បានយកចិត្តទុកដាក់ទៅលើការរៀបចំរដ្ឋបាល គាត់បានកសាងនូវគំរូការិយាល័យ ធិបតេយ្យដែលមានលក្ខណៈពិសេស ៦ យ៉ាងដូចតទៅ ៖

### *១.១សមត្ថកិច្ចបច្ចេកទេស*

និយោជិតក្នុងអង្គការចាត់ចែង ត្រូវបានជ្រើសតាំង និងតំឡើងតួនាទីដោយផ្អែកលើ មូលដ្ឋាន និងបច្ចេកទេស។

## ១.២ឋានានុក្រមនៃអាជ្ញាធរ

អង្គការចាត់តាំងបែបការិយាល័យធិបតេយ្យផ្សារភ្ជាប់ទំនាក់ទំនងរបស់អ្នកគ្រប់គ្រងថ្នាក់ខ្ពស់ទៅនឹង អ្នកក្រោមឱវាទតាមរយៈឋាននុក្រមមួយនៃអាជ្ញាធរ។

## ១.៣ច្បាប់ និងបទប្បញ្ញត្តិ

ភារកិច្ចការទទួលខុសត្រូវនិងសមត្ថកិច្ចរបស់និយោជិតបែបការិយាល័យធិបតេយ្យ ត្រូវបានកំណត់ដោយច្បាប់ជាក់លាក់។

## ១.៤ការបែងចែកពលកម្ម

អង្គការចាត់តាំងបែបការិយាល័យធិបតេយ្យ ប្រើប្រាស់សំព័ន្ធភាពនៃការបែងចែក ពលកម្ម និយោជិតដែលបានអនុវត្តការងារ កំណត់បញ្ជាក់នូវមុខការ។

## ១.៥ឯកសារជាលាយលក្ខអក្សរ

រាល់ការសំរេចចិត្ត សកម្មភាព និងក្បួនច្បាប់រដ្ឋបាល ត្រូវបានកសាងឡើងជាឯកសារលាយលក្ខអក្សរ។

## ១.៦កម្មសិទ្ធិ ឬការត្រួតពិនិត្យរបស់អង្គការចាត់តាំងនីមួយៗ

លក្ខណៈពិសេស ចុងក្រោយនៃអងញការចាត់តាំងបែបការិយាល័យ ធិបតេយ្យ គឺកម្ម សិទ្ធិឬការត្រួតពិនិត្យរបស់អង្គការចាត់តាំងទាក់ទងនឹងទ្រព្យសម្បត្តិ តួនាទី នៃអង្គការចាត់ តាំងរបស់ខ្លួន។

## ២.កំណើតដែលទាក់ទងនិងការកកើតអត្ថបទគតិយុត្ត

តាមលោក John Lock គាត់គឺជាអ្នកទ្រឹស្តីនិយមខាងលោកសេរី ដែលបានរកឃើញនូវគំនិតមួយចំនួន ដែលទាក់ទងនិងបុគ្គលភាពគតិយុត្តរបស់មនុស្ស។

– មនុស្សគ្រប់រូបសុទ្ធតែមានសិទ្ធិរបស់ខ្លួន ដែលសិទ្ធិនោះ គឺជាសិទ្ធិផ្ទាល់របស់ខ្លួន ដែលសិទ្ធិនោះគេហៅថា ជាបុគ្គលភាពគតិយុត្ត (ច្បាប់ទទួល ស្គាល់) ដែលនាំឲ្យមនុស្សគ្រប់រូប ត្រូវតែមានសិទ្ធិផ្ទាល់ខ្លួន។

– លក្ខណៈធម្មជាតិ ដែលមនុស្សមានពីកំណើត ត្រូវតែផ្តល់ឲ្យដោយរដ្ឋ និងទទួលស្គាល់ជាបន្តបន្ទាប់រហូតបានទទួលការឯកភាពគ្នាទាំងអស់គ្នា។

– ឲ្យមនុស្សទាំងអស់ចូលរួមរស់នៅជាមួយគ្នាជាសង្គម ដើម្បីស្វែងរកនូវសន្តិសុខ សន្តិភាព សុវត្ថិភាព និងការថែរក្សានូវទ្រព្យសម្បត្តិកម្មមសិទ្ធិរបស់ខ្លួនឲ្យបានគង់វង្ស។ ដូច្នេះ ត្រូវតែរួមគ្នាបងកង្កើតអត្ថបទច្បាប់ ហើយនាំគ្នាអនុវត្តទាំងអស់គ្នា ឬបង្កើតនូវស្ថាប័នណាមួយ សម្រាប់សម្រេចសេចក្តីនៅពេលមានទំនាស់ណាមួយ។

– តម្រូវឲ្យមានមនុស្សទាំងអស់ បំបាត់នូវភាពឯកកោ បំបាត់នូវការខ្វះមិត្តភាព ការខ្វះនូវដៃគូរ មានន័យថាអ្នកទាំងអស់គ្នា ត្រូវតែចេះទំនាក់ទំនងឲ្យបានស្អិតរមួត។

– មនុស្សទាំងអស់និងទទួលបាននូវផលប្រយោជន៍ នៅពេលដែលបានចាកចេញ ពីភាពធម្មជាតិសុទ្ធសាធ ចាកចេញពីភាពអសន្តិសុខ បញ្ហាចាញ់ប្រៀបគ្នាទៅវិញទៅមក តាមរយៈនៃការប្រើប្រាស់អត្ថបទច្បាប់សម្រាប់ដោះស្រាយ។

– ដើម្បីបញ្ចប់នូវសង្គ្រាមមិនចេះឈប់ឈរ ដែលកើតឡើងរវាងមនុស្សនិងមនុស្ស លើគ្រប់ស្រទាប់វណ្ណៈទាំងអស់។

– ដើម្បីឲ្យមនុស្សទាំងអស់រស់នៅក្នុងសង្គមទំនើបស៊ីវិល័យទទួលបាននូវគ្រប់តំរូវការនៃការវិវត្តន៍របស់ខ្លួន គឺត្រូវជំនះឲ្យបានតាមរយៈការរស់នៅពីធម្មជាតិ ហើយច្នៃប្រឌិតស្របតាមកាលៈទេសៈ និងពេលវេលា។

– រដ្ឋាភិបាល គួរតែបំរើឲ្យប្រជាពលរដ្ឋភាគច្រើន ដែលពួកគាត់បានឯកភាពគ្នា(តំរូវការរបស់ប្រជាពលរដ្ឋ)។

– រដ្ឋាភិបាល ដែលទទួលបាននូវការគាំទ្រ ចេញពីប្រជាពលរដ្ឋ។

– រដ្ឋាភិបាល ដែលបំរើឲ្យប្រជាពលរដ្ឋ ក្នុងនាមជាអាជ្ញាធររបស់រដ្ឋ។

– រដ្ឋាភិបាល គឺដើរតួជាប្រព័ន្ធរួមមួយ នៃសកម្មភាពមួយក្នុងការការពាររាល់សមិទ្ធិផលទាំងឡាយដែលមាន និងរៀបចំទិសដៅអនាគត់ ឲ្យកាន់តែប្រសើរ។ ប៉ុន្តែប្រសិនបើមានការបំពារបំពានទាំងសិទ្ធិ និងកាតព្វកិច្ច ពលរដ្ឋទាំងអស់និងមានសិទ្ធិធ្វើបដិវត្តន៍បន្តទៀត ដែលជាបុព្វហេតុ ដើម្បីការការពារនូវសិទ្ធិផលទាំងអស់នោះ។

– រដ្ឋាភិបាល ពុំមានសិទ្ធិធ្វើលអ្វីតាមទំនើងចិត្តឡើយ អ្វីដែលរដ្ឋាភិបាលអាចធ្វើបាន គឺគ្រាន់តែជាទិសដៅ នៃការចង្អុលបង្ហាញ អំពីកត្តារីកចំរើន កត្តាអភិវឌ្ឍន៍ និងកត្តាជំរុញនានា ដែលនាំឲ្យមានការអភិវឌ្ឍន៍។

ទាំងអស់នេះ បានបង្ហាញអំពីគន្លឹះនៃការកកើតនៃទ្រឹស្តីរធមនុញ្ញ ហើយត្រូវបានប្រទេសសេរីមួយចំនួន ទទួលយកមកបង្កើតអត្ថបទរបស់ខ្លួន ដើម្បីឆ្ពោះរកការបង្កើតរដ្ឋធម្មនុញ្ញ ដើម្បីគ្រប់គ្រងប្រទេសរបស់ខ្លួន។

## ៣.ទ្រឹស្តីរបស់លោក Thomas Paine

ទ្រឹស្តីរបស់លោក Thomas Paine (ស.វទី១៨) ជនជាតិអង់គ្លេស គាត់បានធ្វើដំណើរមក សហរដ្ឋអាមេរិក ដើម្បីផ្សព្វផ្សាយពីទ្រឹស្តីរបស់គាត់ ដល់ប្រជាជនសហរដ្ឋអាមេរិក ដែលទ្រឹស្តីរបស់គាត់នោះគឺ "អ្នកសេរីនិយម"

- យល់ដឹងពីសេរីភាពបុគ្គល ដែលខ្លួនមាន
- យល់ដឹងពីការគ្រប់គ្រងអំណាច ក្នុងដៃរបស់រដ្ឋ មកលើប្រជាពលរដ្ឋ
- ការងើបឡើងក្នុងការតស៊ូប្រយុទ្ធប្រឆាំង ពីរបបរាជានិយម
- ប្រទេសជាតិត្រូវតែពង្រីកនូវវិសាលភាព តាមរយៈពាណិជ្ជកម្ម ការប្រកួតប្រជែង នៃការប៉ុនប្រសព្វរបស់បុគ្គលម្នាក់ៗ
- ការបែងចែកនូវតំបន់ ដើម្បីឲ្យពលរដ្ឋសហរដ្ឋអាមេរិក ធ្វើឲ្យស្របបទៅតាម ការវិវត្តិ នៃសង្គមដោយសន្តិវិធី
- ពេលដែលសង្គមជាតិទទួលបានផល នាំឲ្យបុគ្គលភាពគតិយុត្ត ក៏ទទួលបាន ផងដែរ

បន្ទាប់ពីគាត់បានធ្វើការបដិវត្តនៅសហរដ្ឋអាមេរិក បានជោគជ័យ គាត់ក៏បានធ្វើ បដិវត្តបន្តទៀតដូចជា ប្រទេសបារាំង... ប៉ុន្តែមុនគាត់ទៅប្រទេសបារាំងគាត់ បានបង្កើតអត្ថបទមួយឈ្មោះថា "Comon Sense" ដែលបញ្ជាក់ពីឯករាជ្យភាព របស់សហរដ្ឋអាមេរិក ដែលក្នុងនោះនិយាយពីការទាមទារ សេរីភាពរបស់បុគ្គល ទ្រឹស្តីនៃឯករាជ្យភាព បាតុភូតការកកើតតាមលក្ខណៈធម្មជាតិ ឲ្យស្តែងមកកាន់មនុស្ស និងឆ្ពោះទៅកាន់សង្គមឲ្យមានការរីកចំរើន។

## ៤.Oliver Wendell Holmes, Jr.

Oliver Wendell Holmes កើតនៅថ្ងៃ ០៨ ខែ មិនា ឆ្នាំ ១៨៤១ និង ស្លាប់នៅថ្ងៃ ០៦ ខែ មិនា ឆ្នាំ ១៩៣៥។គាត់កើតនៅទីក្រុង Boston, រដ្ឋ Massachusetts

គាត់ជាកូនរបស់អ្នកនិពន្ធសៀវភៅ និង ជាទស្សនៈវិទូ Oliver Wendell Holmes, Sr. និង អ្នកស្រី Amelia lee Jackson។

គាត់ជាជំនួយការយុត្តធម៌នៅក្នុងតុលាកាកំពូលនៅសហរដ្ឋអាមេរិចចាប់ពីឆ្នាំ ១៩០២ ដល់ ឆ្នាំ១៩៣២។គាត់ជាអ្នកនិពន្ធម្នាក់ដ៏មានឥទ្ធិពលក្នុងសម័យសង្គ្រាមស៊ីវិលនៅសហរដ្ឋអាមេរិច។ គាត់បាន ជំរុញអោយមានបំលាស់ប្តូរនូវការយល់ឃើញរបស់និតិវិទូអាមេរិចអោយមកប្រកាន់យកនូវ ភាពពិត នៃច្បាប់ដែលផ្សារភ្ជាប់និងសង្គម (Legal realism) ដែលគាត់លើកឡើងថា " the life of the law has not been logic ;it has been experience" ដេលមានន័យថា ជីវិតនៃច្បាប់វាមិនមែនសំដៅលើភាពប្រាកដនិយមនោះទេ, តែវាជាការដកស្រងបទពិសោធន៍។ គាត់បាន ច្រានចោលច្បាប់ ដែលពឹងផ្អែកលើធម្មជាតិ "natural law " និង ប្រកាន់យកព្រមទាំងជំរុញ ការប្រកាន់(Moral Skepticism) មជ្ឈធាតុនិយម រឺ ការជឿជាក់លើសមត្ថភាពរបស់ខ្លួន ជាជាងការពឹងពាក់លើ របស់ក្រៅខ្លួនដែលធ្វើអោយមានការចាប់អារម្មណ៍ យ៉ាងច្រើនពីសំណាក់អ្នកច្បាប់នៅអាមេរិច (Abram vs. United States)នៅឆ្នាំ ១៩១៩។គាត់បានប្រៀបប្រដូចរដ្ឋធម្មនុញ្ញ អាមេរិច ថាជា "ការដកស្រងនូវបទពិសោធន៍ និង ជីវិតមនុស្សគ្រប់គ្នាជាការបង្កើតនូវបទពិសោធន៍"។ គាត់បានលើកឡើង ចំពោះប្រជាពលរដ្ឋថា" យើងទាំងអស់គ្នាគួរតែធ្វើការត្រួតពិនិត្យមើលឡើងវិញនូវការយល់ឃើញ លើភាពមិនពេញចិត្តរបស់យើង ហើយព្រមទទួលយកនូវអ្វីដែលអាក្រក់ដែលជាការពិត ដូចជាការ ស្លាប់ជាដើម" ក្នុងពេលដែលគាត់នៅកាន់តំណែងរបស់គាត់នៅក្នុងតុលាការកំពូល, គាត់ត្រូវបានយល់ ស្របដោយប្រធានាធិបតី Theodore Roosevelt, គាត់ក៏បានគាំទ្រការ រៀបចំសេដ្ឋកិច្ចសាជាថ្មី, និង គាំទ្រការដាក់អោយអនុវត្ត "សេរីភាពនៃការនិយាយស្តី" តាំងពីការអនុម័តលើកដំបូងមកម្លេះ។ ក្នុងមុខតំណែង

និង ការយល់ឃើញប្លែកៗរបស់របស់គាត់ បានជំរុញអោយគាត់ក្លាយ ជាអ្នកនិពន្ធដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញនៅក្នុងជំនាន់នោះ ជាពិសេស គឺនៅក្នុងសៀវភៅ American Progressive។អត្ថបទនិពន្ធរបស់គាត់បាន ជំរុញអោយមានការកែប្រែទស្សនៈរបស់ តំណាងរាស្ត្រ, និតិវិទូ, និង អ្នកសិក្សាស្រាវជ្រាវខាង និតិសាស្ត្រ និងសេដ្ឋកិច្ច។គាត់ជាមនុស្សតែម្នាក់គត់ដែលត្រូវបានJournal of legal studies ប្រសិទ្ធិនាមថាជា និតិបណ្ឌិតសភាចារ្យ ដោយសារតែភាពឆ្លាតវាងវៃ រួមផ្សំនិងភាពក្លាហានរបស់ គាត់ក្នុងការបកស្រាយនិង ពន្យល់សាធារណៈជន អោយយល់ពីបែបបទរបស់សង្គមដែលត្រូវវិវត្ត និង ការមើលឃើញបានវែងឆ្ងាយនៃគតិនយោបាយ។

ទស្សនៈរបស់គាត់នៅតែត្រូវបាន សភាអាមេរិចយកមកគោលការណ៍នៅក្នុងការសំរេចចិត្តអ្វី មួយក្នុងផ្នែកនយោបាយរហូតមកដល់សព្វថ្ងៃនេះ។

## ៥.ខុន ជឺ

លោកខុង ជឺ កើតឆ្នាំ ៥៥១មុនគ.ស ហើយស្លាប់ទៅវិញនៅឆ្នាំ ៤៧៩ មុន គ.ស គឺក្នុងជន្មាយុ ៧២ ឆ្នាំ ។ លោកជាក្មេងកើតក្នុងកុលសម្ព័ន្ធល្អ មានចរិតម៉ឺងម៉ាត់ម៉ត់ចត់ និងជាក្មេងដែលយកចិត្តទុក ដាក់ ទៅលើពិធីការនានាមុនអាយុ ។ ពេលលោកធំឡើងលោកបានក្លាយទៅជាគ្រូដឹកនាំចលនាពិធី បុណ្យ នានាដូចជា ពិធីមង្គលការ ពិធីបុណ្យសែនព្រេនដូនតា នឹងបុណ្យបញ្ចុះសពជាដើម ។

ក្នុងនាមជាទស្សនវិទូម្នាក់ដែរ លោកខុង ជឺ មិនបានសិក្សាទៅលើបញ្ហាកំណាកំណើតនឹងខ្លឹម សារនៃចក្រវាឡនៃមេឃ នោង អំពីជីវិត ក្រៅលោកអ្វីឡើយ។ លោកបានឆ្លើយតបទៅសាវករបស់ខ្លួន ថា « បើមិនស្គាល់ថាអ្វីទៅជាជីវិតផងធ្វើម៉េចនឹងអាចស្គាល់បានថា អ្វីទៅជាសេចក្តីស្លាប់នៃជីវិតទៅ កើត « ហើយ »

បើមិនទាន់ចេះបម្រើមនុស្ស ដូចគ្នាផងធ្វើម៉េចនឹងអានទៅបម្រើឲ្យព្រលឹងអារក្សអ្នកតាបាន » ។ សម្តីទាំងនេះសឲ្យថា លោក ខុន ជឺ យកចិត្តទុកដាក់តែបញ្ហាក្នុងលោកយើងនេះទេ បញ្ហា សង្គមមនុស្សនេះហើយ ។ អាចនិយាយថា ទស្សនវិជ្ជារបស់លោកជាទស្សនវិជ្ជាលោកិយសច្ចៈ។

ទស្សនៈរបស់លោកខុង ជឺ ជាទស្សនៈវិជ្ជាដែលមានការវិត្តនិងការកសាង សង្គម មនុស្ស។ លោកតែងតែផ្សព្វផ្សាយមនោគមវិជ្ជារបសើខ្លួនដើម្បីបណ្តុះបណ្តាលមនុស្សទាំងឡាយឲ្យ ចេះដកខ្លួន ចេញពីជំនឿអកុសលផ្សេងៗក្នុងគោលបំណងឲ្យមនុស្ស ចេះស្រលាញ់ជីវិត ចេះស្រលាញ់ជិវភាពរស់នៅក្នុងសង្គមនិងចេះរកមធ្យោបាយតតាំងប្រឆាំងនិងវបត្តិផ្សេងៗដែល មនុស្ស តែងទៃជួបប្រទេះគ្រប់ៗគ្នាក្នុងដំណើរជីវិតរបស់ខ្លួន។ លោកបានទាញសតិតសម្បជ្ជញ្ញៈរបស់ មនុស្សកុំឲ្យធ្លាក់ចូលទៅក្នុងអន្លង់នៃជំនឿហួសហេតុ លោកបានជំរុញឲ្យមនុស្សចេះពឹងផ្អែកទៅលើ កម្លាំងខ្លួនពូកគេហើយឲ្យចេះជឿលើឆន្ទៈរបស់ខ្លួន ពិសេសត្រូវចេះយការពិចារណាធ្វើជាយាន ។

ទស្សនៈរបស់លោកបានឃ្លាត ឆ្ងាយពិសាសនាយ៉ាងដាច់ស្រឡេះ ។ទស្សនវិជ្ជានេះនិយម តែការកសាងជីវភាពមនុស្សក្នុងលោកកិយ និង សណ្តាប់ធ្នាប់សង្គមប៉ុណ្ណោះ ។ តែពុំបានណែនាំឲ្យ មនុស្សស្គាល់ពីផ្លូវលោកឡើយ ។មូលដ្ឋានគ្រឹះសម្រាប់ការសិក្សារទស្សនវិជ្ជានយោបាយរបស់លោក ខុង ជីពឹងផ្អែកទាំងស្រុងលើគោលការណ៍គុណធម៌ ។ គោលការណ៍នេះបានរីករាលដាលទៅលើគ្រប់ស្មារតីរបស់ប្រជាជនចិនសម័យថ្មីនេះផងដែរ ។

ចំពោះទម្រង់រដ្ឋវិញ លោក ខុង ជឺ បានធ្វើការប្រៀបធៀបទៅនឹងគ្រួសារដ៏សែនធំមួយ ដោយចាត់ទុកថាស្តេចជាឪពុក ។ រដ្ឋប្រភេទនេះមានអត្ថិភាពឡើងដើម្បីធ្វើយ៉ាងណាឲ្យជីវភាព នៅក្នុងសង្គមគ្រួសារ ដ៏សែនធំនេះ ។តាមទស្សនៈរបស់លោក « ស្តេចត្រូវតែផ្គត់ផ្គង់ចិញ្ចឹមថែរក្សា និង បង្ហាត់បង្រៀនដល់ប្រជារាស្រ្ត

ដែលជាកូនចៅរបស់ព្រះអង្គ » ។ ហើយអំណាចនសរដ្ឋប្រភេទនេះ ត្រូវតែជាអំណាចនៃរបបបិតុនិយម ( Patemalism ) ។

លោក ខុង ជឺ មិនបានអំពាវនាវ ឲ្យអមាជិកឆ្ពោះទៅរកសមភាពក្នុងសង្គមឡើយ ។ លោកចាត់ទុកថា នៅក្នុងសង្គមដាច់ខាតត្រូវតែមានប្រភេទពួកអភិជន ពួកមនុស្សសាមញ្ញ និងពួក មនុស្សល្ងង់ខ្លៅ ។ គ្មាននិន្នាការលទ្ធិប្រជាធិបតេយ្យអ្វើឡើយក្នុងទស្សនៈរបស់លោក ។លោកខុងជឺបានរេះគន់យ៉ាងខ្លាំងចំពោះពួកមនុស្សសាមញ្ញ ដែលមិនព្រមទទួលស្គាប់ពីទីតាំង និងតួនាទីរបស់ខ្លួន ពីធម្មជាតិនៅក្នុងសង្គម ។ លោកមានបំណងចង់ឲ្យមនុស្សប្រកដោយ គុណធម៌ចូលកាន់តំណែង ក្នុង លិទ្ធអភិជនាធិបតេយ្យ ( Aristocracy ) ។

បញ្ហាសប្បុរសធម៌ មនុស្សធម៌ លោកខុងជឺ បានឈរលើទស្សនៈថា កូនត្រូវស្តាប់ បង្គាប់ឪពុកម្តាយ និងរាមច្បងរបស់ខ្លួន ។គោលការណ៏នេះ មិនត្រឹមតែត្រូវបានគេយកមកអនុវត្តន៏ក្នុង គ្រួសារតែប៉ណ្ណោះទេ តែថែមទាំងត្រូវបានគ្រប្រតិបត្តិក្នុងសង្គម ទាំងមូលទៀតផង ។ សិលធម៌របស់ លោកខុង ជឺ បបានបង្គាប់ឲ្យមនុស្សគ្រប់វណ្ណៈទាំងអស់នៅក្នុងសង្គមនឹងគ្រប់ស្រទាប់ទាំងអស់នៅក្នុង គ្រួសារត្រូវហ៊ានទទួលស្គាល់នូវកំហុសរបស់ខ្លួន នៅចំពោះមុខច្បាប់ផងដែរ ។

សិលធម៌របស់លោកខុង ជឺ គឺសង្កត់ធ្ងន់ទៅលើទស្សនៈថា មនុស្សម្នាក់ៗត្រូវមានស្មារតីអៀន ខ្មាស់ត្រូវចេះស្វែងយល់ពីអ្វីដែលត្រឹមត្រូវ យុត្តធម៌សម្រាប់ជីវិតរបស់ខ្លួន ។

ទោះបីជាមានការចោទប្រកាន់ពីសំណាក់តស្សនៈផ្សេងៗ ដែលថាទស្សនៈខុងជឺបង្គាប់ឲ្យ មនុស្សស្រលាញ់តែក្រុមបក្សពួកគ្នាគាត់ យ៉ាងណាក៏ដោយក៏យើងនៅតែទទួលថា ទស្សនៈលោកចង់ ឲ្យមនុស្សចេះស្រលាញ់អ្នកដទៃផងដែរ

គ្រាន់តែការស្រលាញ់នេះមិនសូវមានការទូលំទូលាយតែ ប៉ុណ្ណោះគោលបំណងសំខាន់របស់លោក គឺចង់លុបបំបាត់ចោលនូវទស្សនៈអត្តភាព ( Egoism ) ឲ្យចេញអស់ពីស្មារតីមនុស្ស ។

ថ្វីត្បិតតែលោក ចាមនុស្សប្រកបដោយសីលធម៌ពិតមែន ក៏ប៉ុន្តែលោកមិនមែនជា មនុស្សភ្លេចខ្លួននោះឡើយ ។លោកយល់ថា មានពេលខ្លះសប្បុរសជន ឬទស្សវិទូ ក៏ត្រូវហ៊ានប្រឈមមុខ និងជនកំណាចដែលបើកក្រចកបញ្ចេញចង្កូមប្រុងនិងសង្គ្រប់ចាប់យក សប្បុរសជនទៅធ្វើជាទាសកររបស់វា ។

## ៦. ជីវប្រវត្តិសង្ខេបរបស់លោក លោក សង់ សាក់រ៉ូសូ

លោក **សង់ សាក់រ៉ូសូ** គឺជាទស្សនៈវិទូជនជាតិបារាំងម្នាក់ដែលជាអ្នកទ្រឹស្តីនយោបាយ និងក្រម សីលធម៌ (Ethics) ។ លោក **សង់ សាក់រ៉ូសូ** កើតនៅក្រុង **ហ្សឺណែវ ប្រទេសស្វីស** លោកគឺជាមនុស្សដែល កើតចេញពីមនុស្សសាមញ្ញក្នុងត្រកូលក្រីក្រមួយ ដែលម្តាយបានស្លាប់ ចោលតាំងពីពេលដែលលោកកើតបានប្រាំបីថ្ងៃ ចំណែកឯឪពុកមានឈ្មោះ **អីសសាក់ រូស្សូ** ។ ជីវិតរបស់ លោក **សង់ សាក់រ៉ូសូ** បានរសាត់អណ្តែត ផ្សងព្រេងតាំងពីនៅវ័យក្មេងមកម្លេះ ។

### *៦.១ អំពីទ្រឹស្តីរបស់ លោក សង់ សាក់រ៉ូសូ*

នៅក្នុងទ្រឹស្តីនយោបាយរបស់ លោក **សង់ សាក់រ៉ូសូ** បានរៀបរាប់នៅក្នុងស្នាដៃរបស់លោកដ៏សំខាន់ មួយគឺ "**កិច្ចព្រមព្រៀងសង្គម**" ដែលបានសរសេរនៅឆ្នាំ១៧៦២ ។ លោក **សង់ សាក់រ៉ូសូ** មានទស្សនៈថា "**រដ្ឋបានកើតចេញពីទំនោររបស់**

**មនុស្សពីធម្មជាតិ"** ។ លោក ***សង់ សាក់រ៉ូសូ*** បានធ្វើការវិភាគមិនខុសប្លែកពីអ្នកនិពន្ធដ៏ទៃទៀតនៅជំនាន់គាត់នោះទេ ព្រោះថាការវិភាគរបស់គាត់ កើតចេញពីសភាពធម្មជាតិជាមូលដ្ឋាន។

លោក ***សង់ សាក់រ៉ូសូ*** បានបង្កើតឲ្យមានសង្គមមួយក្នុងស្នាដៃរបស់គាត់ ដែលមនុស្ស ស្ថិតនៅចំណុះ សង្គមនោះ ពីព្រោះមនុស្សបានប្រគល់សិទ្ធិ និងសេរីភាពរបស់គេ ។ ប៉ុន្តែមនុស្សនៅតែ រក្សាសេរីភាពរបស់គេ ពីព្រោះសង្គមជាសំណុំនៃមនុស្សទាំងអស់ ហើយគ្មានអ្នកណាម្នាក់បាត់បង់ សេរីភាពរបស់គេទេ ។ សេរីភាព និងសមភាពរបស់គេម្នាក់ៗត្រូវបានធានា ។ សង្គមនយោបាយ ជាអ្នកសង្គ្រោះអ្វីដែលមនុស្សពីក្នុងសភាព ធម្មជាតិ គឺមាន សេរីភាព និងសមភាព ដោយធានាសន្តិសុខរបស់បុគ្គលផងដែរ ។ នៅពេលដែលរដ្ឋកើត មានឡើង បាតុភូតនៃអំណាច ក៏កើតមានជាការ ចាំបាច់ដែរ។

ទ្រឹស្តីរបស់លោក ***សង់ សាក់រ៉ូសូ*** បានចង្អុលបង្ហាញថាអធិបតេយ្យរបស់ប្រជាជនស្ថិតនៅជា របស់ប្រជាជន អធិបតេយ្យនេះពុំអាចផ្ទេរទៅឲ្យជនណាម្នាក់ទៀតបានឡើយ ។ នៅក្នុង កិច្ចសន្យានេះគេមិនអាចប្រគល់ អំណាចទៅឲ្យស្តេចមួយអង្គបានទេ ព្រោះថាការរស់នៅចំណុះស្តេច មិនប្រសើរជាងការរស់នៅក្នុងសភាព ធម្មជាតិទេ ។

## *៦.២ ប្រព័ន្ធរាជាធិបតេយ្យ*

លោក ***សង់ សាក់រ៉ូសូ*** បានឡើកឡើងថាប្រព័ន្ធរាជាធិបតេយ្យ (របរផ្តាច់ការ) ពុំអាចទទួលយកបានទេ ព្រោះថាស្តេចដែលកាន់កាន់អំណាចរបស់ប្រជារាស្ត្រ ហើយប្រជារាស្ត្រមិន ចង់បោះបង់ ។ លោក ***សង់ សាក់រ៉ូសូ*** បានធ្វើការរិះគន់ដល់អ្នកតំណាងផងដែរ ពីព្រោះថាប្រជាធិបតេយ្យមានដើមកំណើតចេញពីប្រជារាស្ត្រ

គឺប្រជារាស្ត្រជាអ្នកកាន់កាប់អធិបតេយ្យ ហើយប្រជារាស្ត្រត្រូវសម្រេចអ្វីៗដោយខ្លួនឯង ។ ដូច្នេះអ្នកតំណាងអាច ធ្វើឲ្យប្រជាធិបតេយ្យក្លាយ ពីល្អទៅជាអាក្រក់បាន ព្រោះតែអ្នកតំណាងមិនប្រាកដថាធ្វើអ្វីដែលជាការជ្រើស រើសតាមបំណងរបស់ប្រជារាស្ត្រ ។ លោក **សង់ សាក់រ៉ូសូ** មិនយល់ព្រមឲ្យមានអ្វីៗដែលជារបបអ្នកតំណាង ឡើយ គាត់បានលើកឡើងថា **"កាលណាមានការបោះឆ្នោតហើយ បើគ្មានការធានាចំពោះអ្នកតំណាងទេ នោះប្រជារាស្ត្របានលក់សេរីភាពរបស់គេហើយ"** ។

## ៦.៣ ប្រព័ន្ធប្រជាធិបតេយ្យ

លោក **សង់ សាក់រ៉ូសូ** បានឡើកឡើងនូវមធ្យោបាយមួយចំនួនដើម្បីរៀបចំរបបនយោបាយ មួយដែល ត្រូវធានាសេរីភាពរបស់ប្រជារាស្ត្រ ។ ជាគោលការណ៍របស់ប្រជាធិបតេយ្យ គឺប្រជាជន ទាំងមូលជាម្ចាស់អធិប-តេយ្យ ហើយប្រជារាស្ត្រខ្លួនឯងជាអ្នកប្រើប្រាស់អធិបតេយ្យនោះ ។ ប្រជារាស្ត្របានប្រើប្រាស់អធិបតេយ្យរបស់ គេដោយការបង្កើតឲ្យមានច្បាប់ ។ ច្បាប់គឺជាសេចក្តីប្រកាសជាសាធារណៈ និងបង្ហាញអំពីឆន្ទៈទូទៅមួយ ទៅលើកម្មវត្ថុរួមមួយ។ ប្រភពនៃច្បាប់ គឺជា ឆន្ទៈរួមទូទៅរបស់ប្រជារាស្ត្រ ។

រាល់ការសម្រេចដែលអាចយកជាផ្លូវការបានទាល់តែមានប្រជារាស្ត្រទាំងមូលជាអ្នកសម្រេច គឺស្រប តាមឆន្ទៈរបស់ប្រជារាស្ត្រទាំងមូល ។ ច្បាប់គឺជាគោលដៅទូទៅសម្រាប់គោលការណ៍ធំៗ មិនមែនចែងអំពីបញ្ហា លំអិតដែលជាកិច្ចការរបស់រដ្ឋាភិបាលទេ ហើយនៅក្នុងការអនុវត្តច្បាប់ ក៏ដូចគ្នា ផងដែរ គឺប្រជារាស្ត្រគ្រប់រូបទាំងអស់ត្រូវតែអនុវត្តតាម ។ ច្បាប់ដែលប្រជារាស្ត្រខ្លួនឯង មិនបានអនុមតិ មិនមែនជាច្បាប់ទេ បើរាស្ត្រខ្លួនឯង មិនបានធ្វើអន្តរាគមន៍ដោយផ្ទាល់ យ៉ាងហោច

ណាស់ក៏មានប្រជាមតិទទួលយលើព្រមពីរាស្ត្រដែរ (Accepta- tion of Referendum)។ លោក **សង់ សាក់រ៉ូសូ** បានធ្វើការរិះគន់ផងដែរទៅលើទ្រឹស្តីរបស់លោក **ម៉ុង តេស្បឺ** ដែលបានពោលថា **"អធិបតេយ្យរួមមានតែមួយ គឺអធិបតេយ្យសង្គម"** ។ នៅក្នុងលក្ខណខណ្ឌនេះ រាជាធិបតេយ្យក្តី (Monarchy) អភិជនាធិបតេយ្យក្តី (Aristocracy) អប្បជនាជនធិបតេយ្យក្តី (Oligachy) មានអាចមានទីកន្លែងរបស់ខ្លួន នៅក្នុងប្រព័ន្ធនយោបាយរបស់លោក **សង់ សាក់រ៉ូសូ** ទេ ។

លោក **សង់ សាក់រ៉ូសូ** បានយល់ឃើញថា ច្បាប់មិនអាចមានគ្រោះថ្នាក់ដល់សេរីភាពរបស់ បុគ្គលបាន ទេ ព្រោះថាច្បាប់បានកើតចេញអំពីការសម្រេចរបស់មនុស្សទាំងអស់ ហើយអនុវត្តចំពោះ ទាំងអស់គ្នា ដូច្នេះមិន មានបច្ច័យណាមួយដែលអាចឲ្យទោសដល់មនុស្សទាំងអស់នោះទេ ។

មកដល់បច្ចុប្បនេះទ្រឹស្តីអំពីប្រជាធិបតេយ្យរបស់ លោក **សង់ សាក់រ៉ូសូ** បានរីកសាយភាយពាសពេញ សាកលលោកដោយមានចារិកចេញតាមរយៈរដ្ឋធម្មនុញនៃ ប្រទេសនី មួយៗ ហើយបានលាយបញ្ចូលនៅទ្រឹស្តី របស់លោកផងដែរចំពោះប្រទេសដែលកាន់នូវរបប ប្រជាធិបតេយ្យ។ ការប្រកាន់នូវរបបប្រជាធិបតេយ្យគឺជា រឿងដែលធ្វើឲ្យប្រទេសមានការរីកចំរើន តែផលវិបាកក៏មានផងដែរចំពោះការមិនគោរពឲ្យបានពេញលេញ នូវអ្វីដែលបានធ្វើហើយនោះ ៕

## ៧.**ទស្សនៈលោក**G.W.F HEGEL

លោក **HEGEL** បាននាំមកនូវស្នាដៃយ៉ាងច្រើន នៅក្នុងទ្រឹស្តីយ៉ាងច្រើនក្នុងការបង្កើតរដ្ឋ របបនយោបាយ និង ទំរង់គ្រប់គ្រងរដ្ឋ ។ នៅក្នុងរូបភាពជាទូទៅ ទស្សនវិជ្ជានយោបាយ និងទស្សនវិជ្ជាច្បាប់ លោកបានដាក់ក្នុងសំនេររបស់ខ្លួនស្តីពីទស្សនវិជ្ជាច្បាប់។

## ៧.១ទស្សនវិជ្ជាច្បាប់

ទស្សនវិជ្ជាច្បាប់របស់លោក HEGEL គឺជាទ្រឹស្តីនៃទស្សនវិជ្ជាអំពីក្រឹត្យក្រមនៃព្រលឹងដែលឆ្លុះបញ្ចាំងអំពីសេរីភាពនៅក្នុងរង្វង់ច្បាប់។ កម្មវិធីទស្សនវិជ្ជាច្បាប់នៅក្នុងស្នាដៃរបស់លោក គឺជាការស្វែងយល់ជាលក្ខណៈវិទ្យាសាស្ត្រ អំពីរដ្ឋ និង ច្បាប់ក្នុងវិចារណញ្ញាណ មិនមែនជាការបង្គាប់បញ្ជាថា ត្រូវតែធ្វើដូចនេះដូចនោះឡើយ ។ នៅក្នុងទិសដៅនេះ មានទំនាក់ទំនង ទៅនិងបដារពាក្យស្លោកដ៏អស្ចារ្យរបស់លោកយល់ឃើញថា ៉ អ្វីដែលប្រកបដោយវិចារណញ្ញាណនោះវាប្រាកដប្រជាណាស់ ហើយអ្វីដែលប្រាកដប្រជាណាស់ នោះនិងប្រកបដោយវិចារណញ្ញាណ៉។

ច្បាប់បើតាមទស្សនៈរបស់លោក គឺអ្វីដែលកំណត់ដោយឆន្ទៈសេរីភាព ។ សេរីភាព គឺជាផ្នែកមួយដែលត្រូវបានកំនត់ព្រំដែន និង គោលការណ៍នៃឆន្ទៈ ។ ភាពខុសគ្នារវាងសិទ្ធិ និង ច្បាប់លោក បានទទួលស្គាល់ថា មូលអត្ថន័យនៃសិទ្ធិត្រូវបានសរសេរក្នុងច្បាប់ ដែលបានសរសេរដោយសភា ហើយក្នុងច្បាប់ក៏បានចែងអំពីសិទ្ធិដែរ ។ ដូច្នេះសិទ្ធិ គឺជាផ្នែកមួយនៃច្បាប់ដែរបានចែងក្នុងរដ្ឋធម្មនុញ្ញ។

## ៧.២ទស្សនវិជ្ជាភាពខុសគ្នានៃសង្គមស៊ីវិល នយោបាយ និងរដ្ឋ

លោក HEGEL បានបង្ហាញភាពខុសគ្នានៃសង្គមពលរដ្ឋ នយោបាយ និងរដ្ឋ ។ សង្គមពលរដ្ឋតាមទស្សនៈរបស់លោកគឺ មាននៅក្នុងបច្ចុប្បន្នកាលទេ ដែលជាលើលទីមួយ ហើយដែលសិទ្ធិរបសើពលរដ្ឋត្រូវបានគេកំណត់ទទួលស្គាល់។ សង្គមពលរដ្ឋបង្កឲ្យមានបរិយាកាសសំរាប់ការសំរេចគោលបំណងឯកជន និងផលប្រយោជន៏របស់បុគ្គល។ ចំពោះការរីកចំរើននៃទ្រឹស្តីច្បាប់ គឺជាដំណាក់កាលមួយដ៏សំខាន់ ពីព្រោះនៅត្រង់នេះបញ្ហាញនូវទំនាក់ទំនងឯកជនជាពិសេស និង ជារួមហើយបញ្ហានេះ មិនដែលកើតមានកាលពីបុរេសមយ័ ឬមួយនៅក្នុរដ្ឋគំរូប្លាតុង ក៏គ្មានដែល នៅក្នុងសង្គម

សក្តិភូមិ។ នៅក្នុងដំណាក់កាលដែលប្រជាពលរដ្ឋដែលសង្គមពលរដ្ឋមិនទាន់មានសេរីភាពពេញលេញ ពេលនោះមានបាតុភូតសង្គម ជាច្រើនដែលមានការប៉ះទង្គិចទៅនិងផលប្រយោជឯកជន ហើយក៏ធ្វើឲ្យមានការប៉ះពាល់ដល់ដំណើរការរីកចំរើនរបស់សង្គមដែរ។ នៅក្នុងករណីរដ្ឋអំណាចអវិចារណញ្ញាណ ។

លោក **HEGEL** បានរៀបរាប់អំពីសង្គមស៊ីវិលប្រៀបដូចជាសង្គមពោរពេញទៅដោយទំនាស់ ដូចជាសង្គ្រាមទាំងអស់គ្នាប្រឆាំងទៅនិងទាំងអស់គ្នា ។ នៅក្នុងរចនាសម្ពន្ធ័ សង្គមស៊ីវិល លោកបានចែងជាបី ស្រទាប់ ៖ អ្នកធ្វើស្រែចំការ (អធិជន និងកសិករ) ផលិតករ (អ្នកធ្វើ ឧស្សាហ៍កម្ម ឈ្មួញ សិប្បករ ) និង មន្ត្រីរាជការ ។ ការវិវត្តន៍សង្គមស៊ីវិលជាកត្តាធ្វើឲ្យមានការរីកចំរើនដល់ប្រទេសជាតិ ។

នៅក្នុងរដ្ឋទទួលបាននូវសមិទ្ធិផល ជាពិសេស និង ជារូមគឺសីលធម៌ វប្បធម៌ និងអរិយធម៌ ។ សង្គមស៊ីវិល គឺជាប្រពន្ធ័ពលកម្មដែលឆ្លើយតបទៅនិងសេចក្តីត្រូវការ និងស្រេកឃ្លានធ្វើឲ្យមានការដុះដាលផ្នែកកម្មសិទ្ធិឯកជន និង ទ្រង់ទ្រាយជាទូទៅឲ្យជីវភាពប្រជាជនមានលក្ខណៈប្រហាក់ប្រហែល ឬ មានសមភាពនិងគ្នា ។ ទស្សនៈវិចារណញ្ញាណដែលរដ្ឋត្រូវតែផ្តល់ឲ្យ គឺសេរីភាព និងសិទ្ធិ ។

## ៧.៣ទស្សនវិជ្ជាអំពីឋានានុក្រមរបស់រដ្ឋ

ទស្សនៈរដ្ឋរបស់ **HEGEL** ក្នុងនោះបានឆ្លុះបញ្ចាំងបង្ហាញអំពីលក្ខណៈច្បាប់ ដែលរៀប ចំតាមរចនាសម្ពន្ធ័ឋានានុក្រមរបស់រដ្ឋ ដែលត្រូវបានកំណត់ច្បាស់លាស់ ។

អំណាចបីផ្សេងគ្នាដែលកំណត់នូវនយោបាយរដ្ឋគឺនីតិបញ្ញត្តិ អំណាចរដ្ឋាភិបាល និងអំណាចមេដឹកនាំ រដ្ឋ។ លោកបានគិតថារបបនយោបាយដឹកនាំល្អប្រសើរបំផុតគឺរបបរាជាធិបតេយ្យអាស្រយ័រដ្ឋធម្មនុញ្ញ ។

អំណាចនីតិបញ្ញត្តិ គឺជាអំណាសដែលត្រូវបានកំណត់ និងបង្កើតឡើងរួម។ សភា ត្រូវបានបែងចែកជាពីរះ សភាពែរ ត្រូវបង្កើតឡើងដោយឈរលើគោលការណ៍

នៃការ បន្តកេរ្តិ៍មរតក។ សភាតំណាងរាស្រ្ត ត្រូវបានបង្កើតឡើងដោយការជ្រើសរើសពីជួរ ប្រជាពលរដ្ឋ។ ស្ថានភាពទំនាក់ទំនងរវាងរដ្ឋនិងរដ្ឋ ត្រូវកំណត់នៅក្នុងច្បាប់នៃសកម្ម ភាពនយោបាយក្រៅប្រទេស ។ លោក មិនបានបដិសេធនូវលទ្ធភាពក្នុងការបង្កើត ច្បាប់ច្បាប់កិច្ចព្រមព្រៀង និងការចរចាររវាងរដ្ឋ និងរដ្ឋទេ ។

## ៨ ទស្សនៈរបស់លោក ស៊ុន យ៉ាត់សេន

ទស្សនៈរបស់លោក **ស៊ុន យ៉ាត់សេន** កើតចេញពីទ្រឹស្តីៈ

* ទ្រឹស្តីបុរាណរបស់ចិន ជាទស្សនៈ ខុងជឺ ប៉ុន្តែលោក ក៏ស្ថិតនៅលើទីតាំងមួយឆ្ងាយពីជ្រុងនៃទ្រឹស្តីខុងជឺ ព្រោះមានទំនាក់ទំនងច្រើនជាមួយ និងរបបរាជានិយម៉ាន់ជូរី។ តែទោះជាយ៉ាងណាក្តីក៏ កើតចេញពីឫសគុលនៃទស្សនៈខុងជឺ និង លោកផ្ទាល់ ។

*ប្រភពមកពីគោលគំនិតនយោបាយនៃប្រទេសលោកខាងលិច។ជាដំបូងគឺ សេរីនិយម បន្ទាប់មកលោកបានជក់ចិត្តទៅនិងលទ្ធិសង្គមនិយម ។

### *៨.១ទស្សនវិជ្ជាអំពីគំនិតនយោបាយ*

គោលគំនិតនយោបាយ**ស៊ុន យ៉ាត់សេន** ស្ថិតលើគោលការណ៍ ៣ គឺ

នៅឆ្នាំ ១៩០៥ **ស៊ុន យ៉ាត់សេន** បានសរសេរថា ក្នុងដំណាក់កាល ២៦០ ឆ្នាំ ហើយដែលប្រជាជនចិន បានក្លាយជាជនជាតិមួយគ្មានរដ្ឋ។ បន្ទាប់ ពីឆ្នាំ១៩១១នៅពេលដែលអំណាចអធិរាជស៊ិនបានដួលរលំ ៉ គោលការណ៍ជាតិ៉ ហាក់ដូចជានៅមានអត្ថេរភាពនៅឡើយ ហេតុដូចនេះ កម្មវិធីនយោបាយរបស់បក្សជាតិនិយមនៅមានទីតាំងរបស់ខ្លួន ។ ដោយស្ថានភាពប្រឆាំងនិងបដិវត្តន៍ និងការផ្ទុះឡើងនូវសង្គ្រាមស៊ីវិលបានបង្ខំអោយគោលការណ៍នេះ ជួបប្រទះនូវការកែរប្រែយកមូលអត្ថនយ័ថ្មី ។

គោលការណ៍ទី២ : **គោលការណ៍អំណាចប្រជាជន( លទ្ធិប្រជាធិបតេយ្យ)**

គោលការណ៍នេះបានបង្ហាញពីរចនាសម្ពន្ធ័២យ៉ាងយដែលដឹកនាំ សាធារណរដ្ឋនិយម និង លទ្ធិប្រជាធិបតេយ្យនិយម ។ ដូចនេះគេមិនយល់អ្វីដែលហៅថាសិទ្ធិមនុស្ស ។

លោក**ស៊ុន យ៉ាត់សេន** បានបង្ហាញនូវកត្តាចាំបាច់ដើម្បីប្រារព្ធសាធារណរដ្ឋឡើង នៅក្នុងនោះ គឺ គេមិនត្រូវការ ការថែរក្សានូវរូបភាពសក្តិភូមិទេ គេត្រូវការសមភាព ប្រជាជាតិទាំងមូល ។

គោលការណ៍លទ្ធិប្រជាធិបតេយ្យ ត្រូវបានកំណត់ថា ជាស្ថានភាពនៃការចូលរួមដោយប្រាជាពលរដ្ឋក្នុការដឹកនាំរដ្ឋ ។ប៉ុន្តែ**ស៊ុន យ៉ាត់សេន** បានពិនិត្យអំពីអត្ថេរភាពនេះ មានទំហំធំធេងជាងនេះទៅទៀត ដូចជា ស្ថានភាពបង្កើតឲ្យមាន សេរីភាព និង សមភាព ៉ បើសិនជាគ្មានប្រជាធិបតេយ្យសេរីភាព និង សមភាព វាជាសម្រេកឥត បានការ។

រចនាសម្ពន្ធ័ប្រជាធិបតេយ្យបែបចិន គឺប្រជាធិបតេយ្យមួយដែលកើតឡើងដោយ ៉ រដ្ឋថម្មនុញ្ញនៃស្ថាបន័អំណាច ៥ ៉ គឺ នីតិបញ្ញត្តិ នីតិប្រតិបត្តិ នីតិតុលាការ ស្ថាបន័ការត្រួតពិនិត្យ និងស្ថាបន័ការប្រលង។នៅក្នុស្ថាបន័នីមួយៗត្រូវមានក្រុមប្រឹក្សាជាន់ខ្ពស់និង នៅក្នុងអំណាស មូនដ្ឋានត្រូវមានអ្នកគ្រប់គ្រងមួយ ថ្នាក់អភិបាលខេត្ត ។ ចំណុចកំពូលនៃស្ថាបន័គឺប្រជុំពេញអង្គ ។មុខងារស្ថាបន័នីតិបញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ បានរៀបចំក្នុងគោលគំនិតប្រហាក់ប្រហែលនិងប្រទេសលោកខាងលិច ដែរ។អំណាចនេះត្រូវបានត្រួតពិនិត្យ និងប្រលង ត្រូវធ្វើការឆ្លងកាត់នូវការត្រួតពិនិត្យពីសំណាក់ប្រជាជន ដោយមានតំណាងជាអ្នកសំរេច ។

គោលការណ៍ទីបី : **គោលការណ៍ភាពរុងរឿងសម្បូរសប្បាយរបស់ប្រជាជន**

គោលការណ៍នេះ**ស៊ុន យ៉ាត់សេន** យកទ្រឹស្តី សង្គមនិយមមកប្រើ ប៉ុន្តែវាគ្រាន់តែជាលក្ខណះមួយមិនគ្រប់គ្រាន់ទេ ដើម្បីឆ្លើយតបទៅនិងស្ថានភាពប្រទេសចិន ។

ក្នុងគោលការណ៍ទីបី នេះលោកបាន មើលឃើញនូវសមភាពក្នុងការកាន់កាប់ដីស្រែចំការ និងការរារាំចំពោះការកាន់កាប់របស់ពួកមូលធន ។គឺការធ្វើជាតូបនយកម្ម ប្រព្រឹត្តទៅមិនឲ្យបង្ហូរឈាម និង គំរោងឧស្សាហូបនិយកម្មឲ្យពេញផ្ទៃប្រទេស ។

## ៨.៣ទស្សនៈ ស៊ុន យ៉ាត់សេន អំពីអត្ថនយ័នៃរដ្ឋធម្មនុញ្ញ

អត្ថនយ័នៃរដ្ឋធម្មនុញ្ញរបស់ លោក **ស៊ុន យ៉ាត់សេន** គេឃើញមានឥតទ្ធិពល អំពីទំនៀមទំលាប់ នយោបាយចិននិងទស្សនៈលោកខាងលិច។ ការកត់សំគាល់ទី១ គឺស្ថាបន័អំណាចនៃការប្រលងដែលជាស្ថាបន័ឯករាជ្យទទួលមរតក ពីសេនស៊ី ។ ការកត់សំគាល់ទី២ គឺគោលការណ៍បែងចែកអំណាច (ទ្រឹស្តីរបស់ លោកJohn loc និង Montesquieu )ទន្ទឹមនិងនេះ គោលការណ៍បែងចែកស្ថាបន័អំណាចជា ៥ (ទ្រឹស្តីលោក កុងស្តង់ ) គេបានគូសបញ្ជាក់ថាស្ថាបន័អំណាចគ្រប់គ្រង និងស្ថាបន័អំណាច ប្រលងជាស្ថាបន័នីតិប្រតិបត្តិ២ ដែលឯករាជ្យពីគ្នាយ៉ាងដាច់ខាត ។

គេសង្កេតឃើញថាមានទស្សនៈរបស់លោក**ស៊ុន យ៉ាត់សេន** មានការចាប់អារម្មណ៍ នៅក្នុងទស្សនៈវណ្ណៈតស៊ូ ។ លោកគិតថាវណ្ណៈតស៊ូមានតែក្នុងបែបផែនផលិតកម្ម នៃរបបគហិបតីនិយមប៉ុណ្ណោះ។

## ៩.ទស្សនៈវិទូលោក ម៉ៅ សេទុង អំពីការកើត ច្បាប់ និងរដ្ឋ

ចំពោះទស្សនៈលោក **ម៉ៅ សេទុង** នៅក្នុងវិសយ័ច្បាប់ និងរដ្ឋ គឺអាស្រយ័ទៅនិងទ្រឹស្តីរបស់ម៉ាក្ស ដែលបានកំណត់ថា រដ្ឋជាម៉ាស៊ីន ហឹង្សា រីឯច្បាប់គឺជាគោលបំណងរបស់វណ្ណៈ ដែលនៅក្នុងអំណាចបង្កើតច្បាប់អាស្រយ័និងផលប្រយោជន៏ របស់ពួកគេ ។

**ម៉ៅ សេទុង** មើលឃើញថាចិន គឺជាសាធារណរដ្ឋមួយ ដែលមិនអាសរងចាំនូវរចនាសម្ពន្ធ័ ដឹកនាំតាមរបៀបម៉ាក្សនិយមតែមួយមុខទេ ។ពិបាកនិងពន្យល់ណាស់

ហេតុអ្វីបានជា **ម៉ៅ សេទុង** បដិសេធនូវរចនាសម្ព័ន្ធដឹកនាំតាមរបៀបជារដ្ឋសហពន្ធ័ ។ ជាការពិតណាស់រចនាសម្ពន្ធ័សហពន្ធ័និយម អំណាចមជ្ឈឹមត្រូតែទទួលស្គាល់ស្វយ័ភាពអំណាចមូលដ្ឋាន តាមច្បាប់នៅក្នុងប្រទេសតែមួយ ក៏ប៉ុន្តែ **ម៉ៅ សេទុង** អាចយកស្វយ័ភាពតាមរូបភាពសហពន្ធ័តាមបែបសហភាពសូវៀត ។ ការបដិសេធរចនាសម្ពន្ធ័ សហពន្ធ័មិនមែនតែ **ម៉ៅ សេទុង** នោះទេ មេដឹកនាំនៅក្នុងប្រវត្តិសាស្រ្តចិន ជាច្រើនទៀតក៏ដូច្នេះដែរ ។ ត្រង់នេះ **ម៉ៅ សេទុង**មានទស្សនៈ ជាតិនិយមដែលតែងតែចង់បានហើយ នឹកស្រមៃថា ប្រជាជាតិទាំងអស់នឹងរស់នៅក្នុងរង្វង់ចក្រក្រវាលតែមួយ ពីព្រោះរដ្ឋ ប្រៀបដូចជាស្ថាបន័សង្គមធំមួយ ដែលអាចបាត់បង់ទៅវិញ បើគ្មានការអនុវត្តរចនាសម្ពន្ធ័និយមណាមួយដែលសង្គមត្រូវការឡើយ ។

ការអនុវត្តទ្រឹស្តីបដិវត្តន៍ ប្រជាជាតិប្រជាធិបតេយ្យ បានធ្វើឲ្យចិនបានរឹងមាំហើយទីបំផុត **ម៉ៅ សេទុង** បានសម្លឹងមើលឃើញទិសដៅនៃនយោបាយបដិវត្តន៍សកលលោក ។ហេតុដូចនេះ ហើយបានជាទ្រឹស្តី **ម៉ៅ សេទុង** និង ការអនុវត្តរបស់បក្សកុំម្មុយនីសចិន បានធ្វើឲ្យរន្ទឺរនៅលើឆាកអន្តរជាតិយ៉ាងខ្លាំង ។ យ៉ាងណាមិចនៅក្នុងដំណើរអនុវត្តទ្រឹស្តី បដិវត្តន៍ប្រជាជាតិធិបតេយ្យបានកើតឡើង នុវបំរែបំរួលយ៉ាងខ្លាំង ។ ក្នុងនាមជាអន្តរជាតិមួយនោះ ដើម្បីឈានទៅកាន់សង្គមនិយមបដិវត្តប្រជាធិបតេយ្យ បានក្លាយជារូបភាពអំពើហឹង្សា យ៉ាងខ្លាំង នៅទសវត្សឆ្នាំទី ៥០ ទៅ៦០ សភាធពការណ៏នេះ បាននាំមដល់ប្រទេសចិន នូវមហាន្តរាយយ៉ាងខ្លាំង ។ ទ្រឹស្តីរបស់ **ម៉ៅ សេទុង** បានសាយភាយ ទៅទីឆ្ងាយតទៅទៀត ។

# ឯកសារយោង

.ប្រវត្តិគំនិតនយោបាយ និងទ្រឹស្តីរដ្ឋ (បណ្ឌិត **ឈុន ណារ៉េត**) បោះពុម្ពនៅឆ្នាំ ២០០៧ ។

.ប្រវត្តិគនិតនោយបាយ កាម៉ាធុល

.http://www.philosophypages.com/hy/2h.htm

.http://en.wikipedia.org/wiki/Oliver_Wendell_Holmes,_Jr.

## Oliver Wendell Holmes, Jr.

From Wikipedia, the free encyclopedia

Jump to: navigation, search

For the American physician and poet, see Oliver Wendell Holmes, Sr.

**Oliver Wendell Holmes, Jr.**



**Associate Justice of the United States Supreme Court**

**In office**
December 4, 1902[1] – January 12, 1932

| | |
|---|---|
| **Nominated by** | Theodore Roosevelt |
| **Preceded by** | Horace Gray |
| **Succeeded by** | Benjamin N. Cardozo |

**Chief Justice of the Massachusetts Supreme Judicial Court**

**In office**
August 2, 1899 – December 4, 1902

| | |
|---|---|
| **Appointed by** | Winthrop M. Crane |
| **Preceded by** | Walbridge A. Field |
| **Succeeded by** | Marcus Perrin Knowlton |

**Associate Justice of the Massachusetts Supreme Judicial Court**

**In office**

| | |
|---|---|
| | December 15, 1882 – August 2, 1899 |
| **Appointed by** | John Davis Long |
| **Preceded by** | Otis Lord |
| **Succeeded by** | William Loring |
| **Personal details** | |
| **Born** | March 8, 1841<br>Boston, Massachusetts |
| **Died** | March 6, 1935 (aged 93)<br>Washington, D.C. |
| **Spouse(s)** | Fanny Bowditch Dixwell |
| **Military service** | |
| **Allegiance** |  United States |
| **Service/branch** | US Army |
| **Years of service** | 1861-1865 |
| **Rank** | Captain |
| **Unit** | 20th Massachusetts Volunteer Infantry. |
| **Battles/wars** | American Civil War |

**Oliver Wendell Holmes, Jr.** (March 8, 1841 – March 6, 1935) was an American jurist who served as an Associate Justice of the Supreme Court of the United States from 1902 to 1932, and as Acting Chief Justice of the United States January–February 1930. Noted for his long service, his concise and pithy opinions and his deference to the decisions of elected legislatures, he is one of the most widely cited United States Supreme Court justices in history, particularly for his "clear and present danger" opinion for a unanimous Court in the 1919 case of *Schenck v. United States*, and is one of the most influential American common law judges, honored during his lifetime in Great Britain as well as the United States. Holmes retired from the Court at the age of 90 years, 309 days, making him the oldest Justice in the Supreme Court's history. He also served as an Associate Justice and as Chief Justice on the Massachusetts Supreme Judicial Court, and was Weld Professor of Law at the Harvard Law School, of which he was an alumnus.

Profoundly influenced by his experience fighting in the American Civil War, Holmes helped move American legal thinking towards legal realism, as summed up in his maxim: "The life of the law has not been logic; it has been experience."[2] Holmes espoused a form of moral skepticism and opposed the doctrine of natural law, marking a significant shift in American jurisprudence. As he wrote in one of his most famous decisions, his dissent in *Abrams v. United States* (1919), he regarded the United States Constitution as "an experiment, as all life is an experiment" and believed that as a consequence "we should be eternally vigilant against attempts to check the expression of opinions that we loathe and believe to be fraught with death."[3] During his tenure on the Supreme Court, to which he was appointed by President Theodore Roosevelt, he supported efforts for economic regulation and advocated broad freedom of speech under the First Amendment. These positions as well as his distinctive personality and writing style made him a popular figure, especially with American progressives,[4] despite his deep cynicism and disagreement with their politics.[5] His jurisprudence influenced much subsequent American legal thinking, including judicial consensus supporting New Deal regulatory law, and influential schools of pragmatism, critical legal studies, and law and economics. He was one of only a handful of justices to be known as a scholar; *The Journal of Legal Studies* has identified Holmes as one of the three most cited American legal scholars of the 20th century.[6]

## Abrams v. United States

Later that year, however, in *Abrams v. United States*, Holmes was again in dissent. The Wilson Administration was vigorously prosecuting those suspected of sympathies with the recent Russian Revolution, as well as opponents of the war against Germany. The defendants in this case were socialists and anarchists, recent immigrants from Russia who opposed the apparent efforts of the United States to intervene in the Russian civil war. They were charged with violations of the 1918 amendments to the Espionage Act which were known as the Sedition Act of 1918, and which purported to make criticisms of the government and the war effort a crime. Abrams and his co-defendants were charged with distributing leaflets that in Yiddish called for a "general strike" to protest the US intervention in Russia. A majority of the Court voted to uphold the convictions and sentences of ten and twenty years, to be followed by deportation. Holmes was moved to dissent. The majority claimed to be following the precedents already set in Schenck and the companion cases in which Holmes had written for the Court, but Holmes insisted that the defendants' leaflets neither threatened to cause any harm, nor showed the specific intent to hinder the war effort. Holmes condemned the Wilson Administration's prosecution, and its insistence on draconian sentences for the defendants in passionate language: "Even if I am technically wrong [regarding the defendants' intent] and enough can be squeezed from these poor and puny anonymities to turn the color of legal litmus paper . . . the most nominal punishment seems to be all that possibly could be inflicted, unless the defendants are to be made to suffer, not for what the indictment alleges, but for the creed that they avow. . . " Holmes then went on to explain the importance of freedom of thought in a democracy:

"[W]hen men have realized that time has upset many fighting faiths,they may come to believe . . . that the best test of truth is the power of the thought to get itself accepted in the competition of the market, and that truth is the only ground upon which their wishes can safely be carried out. That, at any rate, is the theory of Constitution. It is an experiment, as all life is an experiment."

In writing this dissent, Holmes may have been influenced by Zechariah Chafee's article "Freedom of Speech in War Time"[24] Chafee had criticized Holmes's opinion in *Schenck* for failing to express in more detail and more clearly the common-law doctrines upon which he relied. In his Abrams dissent, Holmes did elaborate somewhat on the decision in *Schenck*, roughly along the lines that Chafee had suggested. Although Holmes evidently believed that he was adhering to his own precedent, some later commentators accused Holmes of inconsistency, even of seeking to curry favor with his young admirers.[25] In *Abrams*, the majority opinion did rely on the clear-and-present-danger formulation of *Schenck*, claiming that the leaflets showed the necessary intent, and ignoring the point that they were unlikely to have any effect. In later opinions, the Supreme Court departed from this line of reasoning where the validity of a statute was in question, adopting the principle that a legislature could properly declare that some forms of speech posed a clear and present danger, regardless of the circumstances in which they were uttered. Holmes continued to dissent.

## Buck v. Bell

In 1927, Holmes wrote the 8-1 majority opinion in the *Buck v. Bell* case that upheld the forced sterilization of Carrie Buck who was claimed to be mentally defective. although later scholarship has shown the suit was collusive, and Carrie Buck was probably of normal intelligence, the record before the Supreme Court showed only that she had received a proper hearing in which she was represented by a competent guardian, and was able to press her suit in the federal courts. She apparently had received the procedures required by due process of law in ample measure. The argument made on her behalf was principally that the statute requiring sterilization of institutionalized persons was unconstitutional, itself a violation of what today we call "substantive due process." Holmes repeated familiar arguments that statutes would not be struck down if they appeared on their face to have a reasonable basis. In support of his argument that the supposed science of eugenics provided a reasonable basis for the law, and that interest of the states in a pure gene pool outweighed the interest of individuals in their bodily integrity, he argued:

> "We have seen more than once that the public welfare may call upon the best citizens for their lives. It would be strange if it could not call upon those who already sap the strength of the State for these lesser sacrifices, often not felt to be such by those concerned, to prevent our being swamped with incompetence. It is better for all the world, if instead of waiting to execute degenerate offspring for crime, or to let them starve for their imbecility, society can prevent those who are manifestly unfit from continuing their kind. The principle that sustains compulsory vaccination is broad enough to cover cutting the Fallopian tubes. Three generations of imbeciles are enough."[26]

Although the opinion is universally condemned, and the supposed science of eugenics has been discarded, the decision in the case still stands: a person found to be incompetent after adequate procedures may be required to submit to intrusive medical procedures. Buck v. Bell is still the law,to this extent, and was cited in support of the decision in Roe v. Wade.

From Taft's departure on February 3, 1930 until Charles Evans Hughes took office on February 24, 1930, Holmes briefly acted as the Chief Justice and presided over court sessions.

Although Holmes did not dissent frequently, and wrote only 72 separate opinions out of about 1400 written during his 29 years of service, his dissents were often prescient and had acquired so much authority that he became known as "The Great Dissenter".[27]